ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អអក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ៣១៨ សា.១៧ អអក

ភ្នំពេញ, ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០១៧

# សេចក្តីសម្រេច

## ស្តីពីការកំណត់បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ការលក់អគ្គិសនី ក្នុងតំបន់ចែកចាយរបស់ក្រុមហ៊ុន សូហ្វ អេនើជី ខូ អុលធីឌី នៅផ្នែកខ្លះនៃ ស្រុកមង្គលបូរី និងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ សម្រាប់ខួបឆ្នាំ ២០១៧

## អាជ្ញាធរអគ្គិសនីកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ០៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី
- បានឃើញប្រកាសរបស់ក្រសួងរ៉ែ និងថាមពល លេខ៤២១.រ៉ថ.អរ៉ថ.ប្រក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ការអនុវត្តបន្តពីឆ្នាំ ២០១៧-២០២០
- យោង "នីតិវិធីសម្រាប់អនុវត្តការឧបត្ថម្ភធន ដើម្បីបន្ថយថ្លៃអគ្គិសនី" ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលសម្រេចដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា
- យោងអាជ្ញាបណ្ណលេខ៣២៣.អ ដែលបានចេញឲ្យក្រុមហ៊ុន សូហ្វ អេនើជី ខូ អុលធីឌី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១
- យោងការគណនាចំណូលចំណាយអាជីវកម្មរបស់អ្នកកាន់អាជ្ញាបណ្ណ
- យោងការពិគ្រោះយោបល់សាធារណៈចាប់ពីថ្ងៃទី២១ ខែកុម្ភៈ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១៧
- យោងការសម្រេចនៃសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលើកទី៣១០ ថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១៧

## សម្រេច

### ប្រការ១

កំណត់បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ឲ្យក្រុមហ៊ុន សូហ្វ អេនើជី ខូ អុលធីឌី ដែលបន្ទាប់ពីនេះទៅហៅថា "អ្នកចែកចាយអគ្គិសនី" អនុវត្តលើវិក្កយបត្រអគ្គិសនីចេញឲ្យ **អ្នកប្រើប្រាស់អគ្គិសនី** ដែលភ្ជាប់ចរន្តប្រើប្រាស់អគ្គិសនីពីបណ្តាញចែកចាយរបស់ខ្លួន ចាប់ពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ ដល់ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ ទៅតាមប្រភេទលក្ខខណ្ឌ និងអត្រា ដូចក្នុងតារាងខាងក្រោម ៖

| លេខរៀង ប្រភេទ និងលក្ខខណ្ឌនៃការប្រើប្រាស់ | អត្រាថ្លៃលក់ |
|---|---|
| ១. អ្នកប្រើប្រាស់ប្រភេទបូមទឹកធ្វើកសិកម្ម ពេលយប់ ពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក ដែលមាននាឡិកាស្ទង់ដោយឡែក កំណត់ដោយមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ | 480 រៀល / kWh |
| ២. អ្នកប្រើប្រាស់ប្រភេទគេហដ្ឋាន ដែលប្រើមិនលើស ១០ គីឡូវ៉ាត់ម៉ោង ក្នុង ១ ខែ និងទិញអគ្គិសនីតាមខ្សែបណ្តាញតង់ស្យុងទាប របស់ "អ្នកចែកចាយអគ្គិសនី" | 480 រៀល / kWh |

18

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

| | |
|---|---|
| ៣. អ្នកប្រើប្រាស់ប្រភេទគេហដ្ឋាន ដែលប្រើចាប់ពី ១១ ដល់ ៥០ គីឡូវ៉ាត់ម៉ោង ក្នុង ១ ខែ និងទិញអគ្គិសនីតាមខ្សែបណ្តាញតង់ស្យុងទាប របស់ "អ្នកចែកចាយអគ្គិសនី" | 610 រៀល / kWh |
| ៤. អ្នកប្រើប្រាស់ប្រភេទគេហដ្ឋាន ដែលប្រើចាប់ពី ៥១ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ ឡើង និង ទិញអគ្គិសនីតាមខ្សែបណ្តាញតង់ស្យុងទាបរបស់ "អ្នកចែកចាយអគ្គិសនី" | 790 រៀល / kWh |
| ៥. អតិថិជនទូទាត់ដោយថវិការដ្ឋ និងលំនៅដ្ឋានបរទេស គ្រប់ទំហំប្រើប្រាស់ ដែលទិញ អគ្គិសនីតាមខ្សែបណ្តាញចែកចាយ របស់ "អ្នកចែកចាយអគ្គិសនី" | 790 រៀល / kWh |
| ៦. អ្នកប្រើប្រាស់ដែលទិញអគ្គិសនី តាមនាឡិកាស្ទង់តង់ស្យុងមធ្យម ពីបណ្តាញតង់ស្យុង មធ្យមរបស់ "អ្នកចែកចាយអគ្គិសនី" | 0.1650 $US / kWh |
| ៧. អ្នកប្រើប្រាស់ដែលទិញអគ្គិសនី តាមនាឡិកាស្ទង់ LV ក្រោម ត្រង់ស្វូ MV/LV និងបាន វិនិយោគដាក់ត្រង់ស្វូ នាឡិកាស្ទង់ LV និងឌីស្យុងទ័រ្យូម LV ដោយខ្លួនឯង | 0.1719 $US / kWh |
| ៨. អ្នកប្រើប្រាស់ដែលទិញអគ្គិសនី តាមនាឡិកាស្ទង់ LV ក្រោមត្រង់ស្វូ MV/LV ដែល ត្រង់ស្វូ នាឡិកាស្ទង់ និងឌីស្យុងទ័រ្យូមនេះ វិនិយោគដោយ "អ្នកចែកចាយអគ្គិសនី" | 0.1819 $US / kWh |

*កំណត់សំគាល់* ៖

- ពិតមែនតែអត្រាថ្លៃអគ្គិសនីដែលកំណត់ក្នុងប្រការ ១ ខាងលើ មានអត្រាថ្លៃខ្លះ បានកំណត់ជាដុល្លារសហរដ្ឋអាមេរិក ប៉ុន្តែនេះគ្រាន់តែជាតម្លៃប៉ុណ្ណោះ អ្នកប្រើប្រាស់អគ្គិសនីមានសិទ្ធធ្វើការទូទាត់ជូន "អ្នកចែកចាយអគ្គិសនី" ជាប្រាក់រៀល ដោយគិតតាមអត្រាប្តូរប្រាក់ផ្លូវការរបស់អគ្គិសនីកម្ពុជា នៅថ្ងៃដែលទូទាត់ ដែលបានកំណត់លើមូលដ្ឋាននៃអត្រាប្តូរប្រាក់ផ្លូវការ របស់ធនាគារជាតិនៃព្រះរាជាណាចក្រកម្ពុជា ។
- អត្រាថ្លៃលេខរៀងទី ១ ទី ២ ទី ៣ ទី ៤ និងទី ៥ គឺជា "អត្រាថ្លៃឧបត្ថម្ភធន" ដែលអាចទទួលការឧបត្ថម្ភធនសម្រាប់ប៉ះប៉ូវលទ្ធផលអាជីវកម្មសុបរិញ្ញ ប្រសិនបើ "អត្រាថ្លៃពិត" ដែលបានគណនាតាមគោលការណ៍អាជីវកម្មខ្ពស់ជាង "អត្រាថ្លៃឧបត្ថម្ភធន" ដែលបានកំណត់ ។ ដោយឡែក អត្រាថ្លៃលេខរៀងទី ៤ និងទី ៥ អ្នកប្រើប្រាស់ក្រៅពីលំនៅដ្ឋាន ដែលប្រើអគ្គិសនីប្រចាំខែចាប់ពី ២,០០១ គីឡូវ៉ាត់ម៉ោង ឡើងទៅ ពុំមានការឧបត្ថម្ភធនទេ ។
- ក្នុងបញ្ជីថ្លៃលក់អគ្គិសនីខាងលើ អត្រាថ្លៃលេខរៀងទី ៦ ទី ៧ និងទី ៨ គឺជា "អត្រាថ្លៃកំណត់ដោយពុំមានការឧបត្ថម្ភធន" ។ ហើយអត្រាថ្លៃលេខរៀងទី ៧ និងទី ៨ គឺគិតលើអានុភាពប្រើប្រាស់ចាប់ពី ៥០ អាំពែរ ឡើងទៅ គឺជាអ្នកប្រើប្រាស់ដែលមានសិទ្ធទិញអគ្គិសនីតាមនាឡិកាស្ទង់ក្រោមត្រង់ស្វូ។

## ប្រការ២

កំណត់ "អត្រាថ្លៃពិត" ដែលបានគណនាតាមគោលការណ៍អាជីវកម្ម សម្រាប់អត្រាថ្លៃលេខរៀងទី១ ទី២ ទី៣ ទី៤ និងទី៥ នៃប្រការ១ ខាងលើ ដើម្បីអនុវត្តយន្តការឧបត្ថម្ភធន របស់មូលនិធិអគ្គិសនីការូបនីយកម្មជនបទ សម្រាប់ឆ្នាំ ២០១៧ ដូចខាងក្រោម ៖

| **ប្រភេទ និងលក្ខខណ្ឌនៃការទិញ** | **អត្រាថ្លៃពិត** |
|---|---|
| សម្រាប់អ្នកប្រើប្រាស់ដែលទិញអគ្គិសនីពីខ្សែបណ្តាញតង់ស្យុងទាបទាំងអស់ របស់ "អ្នកចែកចាយអគ្គិសនី" ដែលរួមមានអត្រាថ្លៃលេខរៀងទី១ ទី២ ទី ៣ ទី ៤ និងទី ៥ នៅក្នុងប្រការ ១ ខាងលើ | 1,049 រៀល / kWh |

"អ្នកចែកចាយអគ្គិសនី" អាចទទួលបានការឧបត្ថម្ភធន សម្រាប់ប៉ះប៉ូវលទ្ធផលអាជីវកម្មរបស់ខ្លួន ស្របទៅតាម "នីតិវិធីសម្រាប់អនុវត្តការឧបត្ថម្ភធន ដើម្បីបន្ថយថ្លៃអគ្គិសនី" ដែលសម្រេចដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា ។

**ប្រការ៣**

បញ្ជីថ្លៃលក់អគ្គិសនីថ្មី ក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តលើ "វិក្កយបត្រអគ្គិសនី" ចេញចាប់ពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ តទៅ រហូតដល់មានការកែសម្រួលឡើងវិញ ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ស្របតាមច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។ បញ្ជីថ្លៃលក់អគ្គិសនីពាក់ព័ន្ធ ដែលបានដាក់ឲ្យប្រើប្រាស់មុនសេចក្ដីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ចាប់ពីពេលអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះ។

**ប្រការ៤**

សេចក្ដីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្ត ចំពោះអតិថិជនគ្រប់ប្រភេទក្នុងតំបន់ចែកចាយអគ្គិសនីរបស់ "អ្នកចែកចាយអគ្គិសនី" នៅផ្នែកខ្លះនៃស្រុកមង្គលបូរី និងស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

**ប្រការ៥**

ក្នុងការទិញអគ្គិសនីពី "អ្នកចែកចាយអគ្គិសនី" តាមសេចក្ដីសម្រេចនេះ អតិថិជនប្រភេទតង់ស្យុងមធ្យម ត្រូវរក្សាមេគុណអានុភាព (cosφ) នៃការទទួលរបស់ខ្លួនឲ្យឋិតនៅក្នុងកម្រិតគុណភាព $\cos\varphi \geq 0.9$ ឬ $tg\varphi \leq 0.484$ មានន័យថា អតិថិជនមានសិទ្ធប្រើប្រាស់ថាមពលរ៉េអាក់ទីវ ចេញពីប្រព័ន្ធចែកចាយរបស់ "អ្នកចែកចាយអគ្គិសនី" មិនលើសពីចំនួនកំណត់ ដែលកំណត់ដោយ $\cos\varphi \geq 0.9$ ឬ $tg\varphi \leq 0.484$ ឡើយ ។ ក្នុងករណីដែលអតិថិជនខកខានពុំបានរក្សាមេគុណអានុភាព ឲ្យបានដូចការកំណត់ខាងលើ ដោយប្រើប្រាស់ថាមពលរ៉េអាក់ទីវ ពីប្រព័ន្ធចែកចាយរបស់ "អ្នកចែកចាយអគ្គិសនី" លើសពីចំនួនកំណត់ អតិថិជននោះ ត្រូវបង់ថ្លៃបរិមាណថាមពលរ៉េអាក់ទីវដែលខ្លួនប្រើប្រាស់លើសនេះ តាមអត្រាថ្លៃថាមពលរ៉េអាក់ទីវ ស្មើនឹង ០.០២៥ ដុល្លាអាមេរិក ក្នុង ១ គីឡូវ៉ុលអំពែររ៉េអាក់ទីវម៉ោង (kVArh) ។

**ប្រការ៦**

"អ្នកចែកចាយអគ្គិសនី" និងអតិថិជនគ្រប់ប្រភេទ ដូចក្នុងប្រការ ១ ខាងលើ ត្រូវមានភារកិច្ច អនុវត្តបញ្ជីថ្លៃលក់អគ្គិសនីនេះ ឲ្យមានប្រសិទ្ធភាព។

**ប្រការ៧**

ក្រុមហ៊ុន សូហ្វ អេនើជី ខូ អុលធីឌី មានភារកិច្ចផ្សព្វផ្សាយ អំពីខ្លឹមសារសេចក្ដីសម្រេចនេះ ដល់អតិថិជនរបស់ខ្លួនគ្រប់ប្រភេទ ដែលមានការពាក់ព័ន្ធ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ធី នរិទ្ធ**

ចម្លងជូន ៖
- ក្រសួងរ៉ែ និងថាមពល
- សាលាខេត្តបន្ទាយមានជ័យ
- មន្ទីររ៉ែ និងថាមពល ខេត្តបន្ទាយមានជ័យ
- មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ
- សាលាស្រុកមង្គលបូរី និងស្រុកព្រះនេត្រព្រះ
- សាលាឃុំចំបំា, សាលាឃុំក្លាញ់, សាលាឃុំតាំងយ៉ាប
  "ដើម្បីជូនជ្រាប"
- ក្រុមហ៊ុន សូហ្វ អេនើជី ខូ អុលធីឌី
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**អាជ្ញាធរអគ្គិសនីកម្ពុជា :** ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្ដាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh